Received by NSD/FARA Registration Unit 08/17/2025 1:41:26 PM

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

ថ្ងៃពុធ..១២រោច..ខែជេស្ឋ.......ឆ្នាំរោង..ឆស័ក ព.ស.២៥៦៨

លេខ:..........✓.............

រាជធានីភ្នំពេញ ថ្ងៃទី.០៣.....ខែ.កក្កដា..ឆ្នាំ ២០២៤

# សេចក្ដីជូនព័ត៌មាន

## ស្ដីពីការប្រគល់មកវិញនូវរតនសម្បត្តិជាតិៈ វត្ថុបុរាណខ្មែរចំនួន១៤រូប ពីសារមន្ទីរ Metropolitan Museum of Art នៅទីក្រុងញូវយក ត្រូវបានបញ្ជូនមកដល់កម្ពុជា

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈមានសេចក្ដីរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថាៈ វត្ថុបុរាណខ្មែរចំនួន១៤រូប ត្រូវបានបញ្ជូនពីសារមន្ទីរ Metropolitan Museum of Art ( MET ) នៅសហរដ្ឋអាមេរិក មកដល់ សារមន្ទីរជាតិកម្ពុជា រាជធានីភ្នំពេញ នារសៀលថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០២៤ ក្រោយពីបានប្រកាសព័ត៌មានស្ដីពីការប្រគល់ជូនមកកម្ពុជាវិញ កាលពីខែធ្នូ ឆ្នាំ២០២៣។ ការបញ្ជូនត្រឡប់មកវិញជាប្រវត្តិសាស្ត្រនូវរតនសម្បត្តិជាតិរបស់យើង ពីសារមន្ទីរ MET ដែលជាស្ថាប័នវប្បធម៌ដ៏ធំបំផុតមួយក្នុងពិភពលោក គឺតាមរយៈដំណើរការចរចាអស់ជាច្រើនឆ្នាំ រវាងក្រុមការងារក្រសួងវប្បធម៌និងវិចិត្រសិល្បៈកម្ពុជា ការិយាល័យរដ្ឋអាជ្ញាសហរដ្ឋអាមេរិកប្រចាំសង្កាត់ភាគខាងត្បូងក្រុងញូវយ៉ក( SDNY ) ការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក( HSI ) និងតំណាងសារមន្ទីរ MET។

វត្ថុបុរាណខ្មែរទាំងនេះមានដូចជា ទេពស្រី( នាងឧមា ) ធ្វើពីថ្មភក់ សតវត្សរ៍ទី១០គ.ស. ដែលជារូបចម្លាក់ដ៏ល្អឯកមួយមានប្រភពមកពីរាជធានីកោះកេរ។ នៅឆ្នាំ២០២១ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈបានរកឃើញប្រអប់ជើងនៃបដិមានេះនៅរមណីយដ្ឋានប្រាសាទកោះកេរ និងដោយផ្អែកលើសក្ខីកម្មពីអតីតបុគ្គលដែលបានលួចបញ្ជាក់ថា បដិមានេះត្រូវបានលួចយកចេញនៅឆ្នាំ១៩៩៧។ ទីបំផុត រូបចម្លាក់នាងឧមាអាចផ្គុំជាមួយគ្នាឡើងវិញជារូបបដិមាតែមួយពេញលេញ និងល្អវិចិត្រ។

ចម្លាក់ដ៏កម្រ និងជាស្នាដៃឯកមួយទៀតគឺ បដិមាព្រះលោកេស្វរ ធ្វើពីសំលោហៈ ចុងសតវត្សរ៍ទី១០ ដើម១១គ.ស ដែលសារមន្ទីរ MET បានទិញបដិមានេះពីលោក Douglas Latchford នៅក្នុងឆ្នាំ១៩៩២។ វត្ថុបុរាណដ៏សំខាន់មួយទៀតនោះ គឺព្រះកេសព្រះលោកេស្វរ ធ្វើពីសំរិទ្ធ សតវត្សរ៍ទី១០គ.ស. ដែលកម្ពុជាតែងព្យាយាមស្វែងរក ដើម្បីយកមកផ្គុំឡើងវិញជាមួយនឹងដងខ្លួន បច្ចុប្បន្នកំពុងដាក់តាំងនៅសារមន្ទីរជាតិកម្ពុជា។ ព្រះកេសនេះប្រហែលត្រូវបានគេលួចនៅក្នុងទសវត្សរ៍១៩៩០ រីឯដងខ្លួនត្រូវបានគេរកឃើញនៅក្នុងស្ទឹងមួយក្នុងទសវត្សរ៍១៩៣០ ក្នុងខេត្តបាត់ដំបង។

លោកជំទាវបណ្ឌិតសភាចារ្យ **ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានប្រសាសន៍ថា "ការប្រគល់សម្បត្តិវប្បធម៌របស់ជាតិយើងត្រឡប់មកវិញពីសារមន្ទីរ MET គឺមានសារៈសំខាន់បំផុត មិនសម្រាប់តែប្រទេសកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់មនុស្សជាតិទាំងមូលផងដែរ។ យើងដឹងថា វត្ថុបុរាណខ្មែរជាច្រើនទៀតស្ថិតនៅសារមន្ទីរ MET ដែលយើងសង្ឃឹមថា វត្ថុដ៏មានតម្លៃទាំងនោះនឹងវិលត្រឡប់មកកម្ពុជាវិញ។ យើងមានសេចក្ដីសោមនស្សរីករាយ ដែលអ្នកកាន់កាប់សមុច្ច័យឯកជននានា និងសារមន្ទីរមួយចំនួនបានទាក់ទងមកយើងក្នុងពេលថ្មីៗនេះ ហើយយើងរំពឹងថា មរតកវប្បធម៌សំខាន់ៗដទៃជាច្រើនទៀត នឹងប្រគល់ត្រឡប់មកមាតុភូមិវិញនាពេលអនាគត"។

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី មានប្រសាសន៍បន្តទៀតថា "ការបញ្ជូនត្រឡប់មកវិញជាបន្តបន្ទាប់នូវសម្បត្តិវប្បធម៌ជាតិដែលត្រូវបានគេលួចនាំចេញដោយខុសច្បាប់នេះ គឺសបញ្ជាក់ជាថ្មីម្ដងទៀតនូវការប្ដេជ្ញាចិត្តរបស់កម្ពុជា ក្នុងការបន្តស្វែងរក និងនាំយកមកវិញនូវព្រលឹងដូនតារបស់ខ្លួន ដែលបានឃ្លាតចាកឆ្ងាយពីទឹកដីកំណើត ក្នុង

ទូរសព្ទ / ទូរសារៈ 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

Received by NSD/FARA Registration Unit 08/17/2025 1:41:26 PM

អំឡុងសង្គ្រាមស៊ីវិលនិងអសន្តិសុខច្រើនទសវត្សរ៍កន្លងមកនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូន **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភា ចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិត ដែលបាននាំមកនូវសន្តិភាពពេញលេញជូនជាតិមាតុភូមិ តាមរយៈនយោបាយឈ្នះ-ឈ្នះ។ ព្រមជាមួយនេះ ប្រជាជនកម្ពុជាសូមស្វាគមន៍ការវិលត្រឡប់មកវិញនៃព្រលឹងដូនតាដែលជាមង្គលរបស់ជាតិ ក៏ដូចជាការប្រោះព្រំប្រសិទ្ធិពរជូន **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីថ្មីនៃព្រះរាជាណាចក្រកម្ពុជា"។

លោកជំទាវរដ្ឋមន្ត្រី បានថ្លែងអំណរគុណនិងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការ និងការខិតខំប្រឹងប្រែងរបស់រដ្ឋអាជ្ញាសហរដ្ឋអាមេរិក លោក Damian Williams និងការិយាល័យរដ្ឋអាជ្ញាប្រចាំសង្កាត់ភាគខាងត្បូងក្រុងញូវយ៉ក ជាពិសេសលោកស្រី Jessica Feinstein និងលោក Shiva Logaraja ព្រមទាំងការិយាល័យស៊ើបអង្កេតសន្តិសុខមាតុភូមិ និងភ្នាក់ងារពិសេសគឺលោក John P. Labbat និង លោក Robert Mancene រួមទាំងអាជ្ញាធរពាក់ព័ន្ធទាំងនៅក្រៅប្រទេស និងនៅកម្ពុជា ជាពិសេសថ្លែងអំណរគុណដល់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា និងក្រុមការងារនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ។ ទន្ទឹមនេះលោកជំទាវរដ្ឋមន្ត្រី បានថ្លែងអំណរគុណជាពិសេសចំពោះលោក Bradley J. Gordon ស្ថាបនិកនៃក្រុមហ៊ុន Edenbridge Asia លោក Steven Heimberg នៃក្រុមហ៊ុន Apex Advisors កញ្ញា Melina Antoniadis នៃក្រុមហ៊ុន NOSTOS Strategies និងលោកស្រីសាស្ត្រាចារ្យ Ashley Thompson នៃសកលវិទ្យាល័យ SOAS ដែលបានជួយក្នុងការចរចាទាមទារមកកម្ពុជាវិញនូវសម្បត្តិវប្បធម៌ខ្មែរ នាពេលកន្លងមក។

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក៏បានបញ្ជាក់ថា "ការបញ្ជូនត្រឡប់មកវិញនៃព្រលឹងដូនតានេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការផ្សះផ្សានិងការព្យាបាលរបួសផ្លូវចិត្តរបស់ប្រជាជនកម្ពុជា ដែលបានឆ្លងកាត់សង្គ្រាមស៊ីវិលជាច្រើនទសវត្សរ៍ និងរងគ្រោះដ៏ឈឺចាប់ពីសោកនាដកម្មនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម។ លទ្ធផលប្រកបដោយផ្លែផ្កានេះ ក៏បានបង្ហាញនូវទំនាក់ទំនងកាន់តែរឹងមាំឡើងជាមួយសហរដ្ឋអាមេរិក"។

Received by NSD/FARA Registration Unit 08/17/2025 1:41:29 PM



**បដិមាទេពស្រី (នាងឧមា)**
ថ្មភក់, សម័យអង្គរ, រចនាបថកោះកេរ សតវត្សរ៍ទី១០គ.ស.



**បដិមាអឌ្ឍនារីស្វរ**
សំរឹទ្ធ, មុនសម័យអង្គរ, សតវត្សរ៍ទី៧-៨គ.ស.



**ព្រះកេសព្រះលោកេស្វរ**
សំលោហៈ, សម័យអង្គរ,
សតវត្សរ៍ទី១០គ.ស.



**បដិមាព្រះលោកេស្វរ**
សំលោហៈសម័យអង្គរ ,,
ចុងសតវត្សរ៍ទី១០-ដើម១១គ.ស.



**មុខព្រះឥស្វរ**
សំលោហៈ សម័យអង្គរ រចនាបថ
កោះកេរ សតវត្សរ៍ទី១០គ.ស.

Received by NSD/FARA Registration Unit 08/17/2025 1:41:29 PM